# ការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីសម្រាប់អាណត្តិទី ១២

# និង

# ជ្រើសតាំងក្រុមប្រឹក្សាគណៈមេធាវីសម្រាប់អាណត្តិទី៩

## លទ្ធផលបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីសម្រាប់អាណត្តិទី ១២ និងជ្រើសតាំងក្រុមប្រឹក្សាគណៈមេធាវីសម្រាប់អាណត្តិទី ៩

នៅថ្ងៃអង្គារ ៧កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ នៅសណ្ឋាគារសុខាវ៉េស៊ីដង់ភ្នំពេញ បានរៀបចំមហាសន្និបាតលើកទី ២៣ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធីបតីភាពលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានិងការអញ្ជើញចូលរួមជាអធីបតីពីសំណាក់ ឯកឧត្តម អង្គវង្ស វឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងឯកឧត្តម អ៊ុក សារុំផ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងសមាជិកក្រុមប្រឹក្សាគណៈមេធាវីផងដែរ។

បន្ទាប់ពីលោកមេធាវី ព្រហ្ម វិចិត្រក្ខរា អគ្គលេខាធិការគណៈមេធាវី រាយការណ៍ពីសកម្មភាពការងាររយៈពេលមួយឆ្នាំរបស់គណៈមេធាវី អង្គសន្និបាតបានដំណើរការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីសម្រាប់អាណត្តិទី១២ និងជ្រើសតាំងក្រុមប្រឹក្សាគណៈមេធាវីសម្រាប់អាណត្តិទី ៩។ ជាលទ្ធផល លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីអាណត្តិទី ១១ ត្រូវបានអង្គសន្និបាតបោះឆ្នោតឱ្យបន្តធ្វើជាប្រធានគណៈ មេធាវីសម្រាប់អាណត្តិទី ១២ ទៀត។ ទន្ទឹមនឹងនេះ អង្គសន្និបាតក៏បានបន្តបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាគណៈមេធាវីសម្រាប់អាណត្តិទី ៩ សរុបចំនួន ៣៣ រូបដូចមានរាយនាមដូចខាងក្រោមនេះ៖

| | | |
|---|---|---|
| ១ មេធាវី កុយ នាម | ១២ មេធាវី ហុង គឹមសួន | ២៣ មេធាវី ស៊ុយ ឈុនហាក់ |
| ២ មេធាវី ទេព បូផល | ១៣ មេធាវី ឌុយ សុខសូលីដា | ២៤ មេធាវី គង់ សំអុន |
| ៣ មេធាវី ពេជ្រ សូរិយា | ១៤ មេធាវី សួន ប៊ុនធឿន | ២៥ មេធាវី ហាក់ សៀកលី |
| ៤ មេធាវី ជុំ សុវណ្ណាលី | ១៥ មេធាវី កេង សុម៉ារតន៍ | ២៦ មេធាវី គង់ សុភ័ក្រ្ត |
| ៥ មេធាវី ប៉ា ងួនគា | ១៦ មេធាវី ពិន វណ្ណៈ | ២៧ មេធាវី គាន តារា |
| ៦ មេធាវី ចេង ប៉េងហាប់ | ១៧ មេធាវី ច័ន្ទ វិចិត្រ | ២៨ មេធាវី ហ៊ាង ហុង |
| ៧ មេធាវី យ៉ុង ផានិត | ១៨ មេធាវី ព្រហ្ម វិចិត្រសុភា | ២៩ មេធាវី ឈរ លីថៃ |
| ៨ មេធាវី ចៅ ប៊ុនហួន | ១៩ មេធាវី ណុប គុណថុល | ៣០ មេធាវី ម៉ុម ពិសី |
| ៩ មេធាវី រស់ មុនិន្ទៈ | ២០ មេធាវី យឹម ថាវី | ៣១ មេធាវី ទ្រី សំរស់ |
| ១០ មេធាវី តែ ចំណាន | ២១ មេធាវី ឌឹម ចៅសេង | ៣២ មេធាវី នួន ផានិត |
| ១១ មេធាវី ខូវ ចន្ថា | ២២ មេធាវី លី សុខឡាយ | ៣៣ មេធាវី យុត កែវសុវត្ថា |





## ពិធីផ្ទេរតំណែងសមាជិកក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

នាថ្ងៃច័ន្ទ ១៣កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំការផ្ទេរដំណែងរវាងសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៨ ជូនសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៩ ក្រោមអធិបភាពលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីអាណត្តិទី១២នេះ។ សូមរំលឹកផងដែរថា កាលពីថ្ងៃអង្គារ ៧កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ នៅសណ្ឋាគារសុខាវ៉េស៊ីដង់ភ្នំពេញ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានរៀបចំមហាសន្និបាតលើកទី២៣ របស់ខ្លួនដើម្បីជ្រើសតាំងប្រធានគណៈមេធាវី និងសមាជិកក្រុមប្រឹក្សាគណៈមេធាវី។ លោកមេធាវីមេធាវីសួន វិសាល ប្រធានគណៈមេធាវីអាណត្តិទី១១ ត្រូវបានមហាសន្និបាតបានបោះឆ្នោតគាំទ្របន្តដំណែងសម្រាប់អាណត្តិទី២(២០១៨-២០២០)។

